


ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
東埔寨郵政銀行 CAMBODIA POST BANK PLC.

# ព្រឹត្តិបត្រព័ត៌មាន

ខែកក្កដា ឆ្នាំ២០២៥ | លេខ០៨

## សេដ្ឋកិច្ច និងវិស័យធនាគារ នៅក្នុងប្រទេសកម្ពុជា



កម្ពុជា ជាប្រទេសដែលមានសេដ្ឋកិច្ចតូច និងបើកទូលាយ ដែល ៦០% នៃGDP ពឹងផ្អែកលើការនាំចេញ។ កត្តានេះបានធ្វើឱ្យប្រទេសកម្ពុជា ទទួលរងផលប៉ះពាល់យ៉ាងខ្លាំង ពីការផ្លាស់ប្តូរគោលនយោបាយពាណិជ្ជកម្មសកល និងការកើនឡើងនៃភាពមិនប្រាកដប្រជានានាពីបរិយាកាសខាងក្រៅ។ សហរដ្ឋអាមេរិក គឺជាគោលដៅនាំចេញដ៏ធំបំផុតរបស់កម្ពុជា ស្មើនឹង ៣៩% នៃការនាំចេញសរុប និង ២៩% នៃផលិតផលក្នុងស្រុកសរុប ជិតទ្វេដងនៃការនាំចេញទៅកាន់តំបន់អាស៊ាន ២០% និងសភាពអឺរ៉ុប ១៧% ខណៈដែលប្រទេសចិន ជាប្រទេសដែលកម្ពុជានាំចូលច្រើនជាង(៤៧%) និងមានការវិនិយោគពីបរទេសច្រើនជាងគេផងដែរ។ ការនាំចេញទៅសហរដ្ឋអាមេរិកបានបន្ថែម ៨% ដល់ GDP កម្ពុជា ខណៈការនាំចេញទៅអឺរ៉ុបបន្ថែម ៦% និងប្រទេសចិនបន្ថែម ៣%។ ភាគច្រើននៃទំនិញនាំចេញ គឺជាទំនិញធ្វើដំណើរ សម្លៀកបំពាក់ និងស្បែកជើង ដែលពាក់កណ្តាលត្រូវបាននាំចេញទៅកាន់សហរដ្ឋអាមេរិក ហើយបានផ្តល់ការងារដល់កម្មករប្រហែលមួយលាននាក់ ដែល ៨0% ជាស្ត្រី។

- ឆមាសទីមួយនៃឆ្នាំ២០២៥ ដោយសារការនាំចេញ សេដ្ឋកិច្ចកម្ពុជាមានភាពរឹងមាំ និងអាចធានាកំណើនGDPលើសពី ៤% ក្នុងឆ្នាំ២០២៥ បើទោះបីជាមានការធ្លាក់ចុះខ្លាំង ក្នុងឆមាសទី២ ក៏ដោយ។
- បញ្ហាប្រឈមរបស់កម្ពុជានៅក្នុងឆមាសទី២ ឆ្នាំ២០២៥ និងឆមាសទី១ ឆ្នាំ២០២៦ រួមមាន៖

  √ ការតម្លើងពន្ធរបស់លោក Trump ដែលប៉ះពាល់ផ្ទាល់ទាំងការនាំចេញរបស់កម្ពុជា និងសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក។

  √ ជម្លោះព្រំដែនកម្ពុជា-ថៃ

  √ គ្មានកំណើនឥណទាន និងបញ្ហាឥណទានមិនដំណើរការ

  √ ទីផ្សារអចលនទ្រព្យមិនទាន់ប្រសើរឡើងវិញ

  √ ចំនួនភ្ញៀវទេសចរណ៍នៅមានកម្រិតទាប

- ប៉ុន្តែសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលវែងនៅតែល្អប្រសើរ។ កម្ពុជាទំនងជាប្រទេសមួយ ក្នុងចំណោមប្រទេសជាច្រើន ដែលអាចមានអត្រាកំណើនខ្ពស់បំផុត ដោយសារការវិនិយោគពីបរទេស និងភាគលាភប្រជាសាស្ត្រ។
- កំណើនការងារនៅតែយឺត រីឯសកម្មភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក៏មានការវិវឌ្ឍន៍យឺតយ៉ាវផងដែរ។

ដោយសារប្រឈមនឹងបញ្ហាសកល និងក្នុងប្រទេស ទោះបីសេដ្ឋកិច្ចកម្ពុជាមានភាពប្រសើរឡើងនៅក្នុងត្រីមាសទី១ ឆ្នាំ២០២៥ ក៏ដោយ ក៏កំណើននេះត្រូវបានគេព្យាករណ៍ថានឹងថយចុះមកនៅត្រឹម ៤.0% នៅឆ្នាំ២០២៥ និង ៤,៥% នៅឆ្នាំ២០២៦។

វិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចត្រូវបានរំពឹងថានឹងបន្តប្រសើរឡើង ដែលមួយផ្នែកដោយសារ ទំនាក់ទំនងល្អទាំងក្នុងស្រុក និងក្រៅស្រុក។ ក្នុងប៉ុន្មានឆ្នាំខាងមុខនេះ ផលិតកម្មកសិកម្ម និងឧស្សាហកម្មកែច្នៃកសិផល អាចនឹងល្អប្រសើរ ដោយសារកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគី ជាពិសេសប្រសិនបើបញ្ហាប្រឈមមួយចំនួនក្នុងវិស័យនេះត្រូវបានដោះស្រាយ។

សេដ្ឋកិច្ចកម្ពុជា ដែលពឹងផ្អែកលើប្រាក់ដុល្លារអាមេរិក ប្រែប្រួលតាមគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក ដែលនេះនាំឱ្យមានការកើនឡើងអតិផរណា ដោយសារការផ្លាស់ប្តូរគោលនយោបាយពាណិជ្ជកម្មពិភពលោក ធ្វើឱ្យប៉ះពាល់ដល់អត្រាប្តូរប្រាក់ និងតម្លៃនាំចូលជាប្រាក់ដុល្លារ។ ខណៈការនាំចេញមានភាពយឺតយ៉ាវ ឱនភាពជញ្ជីងពាណិជ្ជកម្មត្រូវបានគេរំពឹងថានឹងកើនឡើងក្នុងរយៈពេលខ្លី។ កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការប្រមូលពន្ធបន្ថែម និងគ្រប់គ្រងការចំណាយត្រូវបានរំពឹងថានឹងកាត់បន្ថយឱនភាពថវិកា។

អតិផរណាបានកើនឡើងដល់ ៣,៧% ក្នុងខែមីនា ឆ្នាំ២០២៥ ដោយសារការកើនឡើងតម្លៃអាហារ។ តម្លៃទំនិញក្នុងស្រុក ហាក់មានការប្រែប្រួលតាមនិន្នាការពិភពលោក។ នៅក្នុងខែមីនា ឆ្នាំ២០២៥ តម្លៃទំនិញមិនមែនម្ហូបអាហារនៅកម្ពុជាបានកើនឡើងបន្តិច 0.៩% បើធៀបនឹងឆ្នាំមុន ដែលបង្ហាញថាអតិផរណាសម្រាប់ទំនិញទាំងនេះមានស្ថិរភាព។

Cambodia GDP Growth (%)




Inflation (% change year-on-year)




កំណើនសេដ្ឋកិច្ចពិភពលោកយឺតជាងការរំពឹងទុកអាចបណ្តាលឱ្យការនាំចេញ និងលំហូរវិនិយោគផ្ទាល់ពីបរទេសមានការថយចុះខ្លាំង។ ការរឹតត្បិតបន្ថែមនៅក្នុងទីផ្សារសំខាន់ៗ ដូចជាសហរដ្ឋអាមេរិកក៏នឹងបង្កហានិភ័យបន្ថែមផងដែរ។ បំណុលឯកជនកម្រិតខ្ពស់ គួបផ្សំនឹងការកើនឡើងលឿនជាងការរំពឹងទុកនៃឥណទានមិនដំណើរការ និងហានិភ័យដែលកើតចេញពីអតិផរណា ដោយសារការកើនឡើងនៃអតិផរណានៅសហរដ្ឋអាមេរិក អាចប៉ះពាល់ដល់ស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ និងជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

វិធានការគោលនយោបាយគួរតែផ្តោតលើ ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុ, ការជំរុញកំណែទម្រង់ពាណិជ្ជកម្ម និងការវិនិយោគ, និងការពង្រឹងសំណាញ់សុវត្ថិភាពសង្គមដើម្បីការពារគ្រួសារដែលងាយរងគ្រោះ។ កម្ពុជាក៏អាចប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងតំបន់ (FTA) រួមមានកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចក្នុងតំបន់ (RCEP) និងអាស៊ានបូក ដើម្បីជួយសម្រួលដល់ការចាប់យកទីផ្សារ និងធ្វើពិពិធកម្មដៃគូពាណិជ្ជកម្មរបស់ខ្លួន ក្នុងតំបន់នានារួមទាំង តំបន់អាស៊ានផងដែរ។

ក្នុងរយៈពេលមធ្យម កម្ពុជាត្រូវតែផ្លាស់ប្តូរ ដោយមិនត្រូវពឹងផ្អែកលើវិស័យសំណង់ អចលនទ្រព្យ និងការនាំចេញសម្លៀកបំពាក់ទៀតទេ សម្រាប់កំណើនសេដ្ឋកិច្ចរបស់ខ្លួន។ កម្ពុជាគួរផ្តោតលើការជំរុញ វិស័យផលិតកម្ម សេវាកម្ម និងកសិកម្ម។ ដើម្បីរក្សាបានកំណើនប្រកបដោយនិរន្តរភាពយូរអង្វែង កម្ពុជាចាំបាច់ត្រូវពង្រឹងធនធានមនុស្ស កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងលើកកម្ពស់តម្លាភាព និងប្រសិទ្ធភាពនៃបទប្បញ្ញត្តិ។ ទន្ទឹមនឹងនេះ ការបង្កើនការកៀរគរប្រាក់ចំណូលក្នុងស្រុកនឹងជួយរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចផងដែរ។

ការកើនឡើងខ្លាំងនៃធនធាន គឺជាតម្រូវការចាំបាច់ ដើម្បីបំពេញតាមគោលដៅអភិវឌ្ឍន៍ និងទ្រទ្រង់ការចំណាយរបស់រដ្ឋាភិបាល ដូចដែលបានបង្ហាញនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ។ ការបន្ថែមការកៀរគរប្រាក់ចំណូលមានសារៈសំខាន់ណាស់ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍របស់កម្ពុជា ពិសេស ការវិនិយោគក្នុងសង្គមលើវិស័យនានា ដូចជាវិស័យសុខាភិបាល និងអប់រំ ដែលការចំណាយនៅលើវិស័យនេះនៅមានកម្រិតទាបនៅឡើយ។ ប្រាក់ចំណូលកាន់តែខ្ពស់ នឹងអនុញ្ញាតឱ្យរដ្ឋាភិបាលពង្រឹងគុណភាពសេវាសាធារណៈ វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងកសាងភាពធន់ ទល់នឹងការប្រែប្រួលអាកាសធាតុ។

ប្រាក់ចំណូលពីភ្ញៀវទេសចរណ៍អន្តរជាតិបានកើនឡើងដល់ ១៨,៧លានដុល្លារអាមេរិក ស្មើនឹង ៥២% នៃចំណូលក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០១៩ កើនឡើងតិចតួចពី ៤៦% ក្នុងឆ្នាំ២០២៤។ ចំណូលពីភ្ញៀវទេសចរណ៍ក្នុងឆ្នាំ២០២៤ ត្រូវបានអាជ្ញាធរកម្ពុជាប៉ាន់ស្មានថា អាចឈានដល់ ៣.៦៣៧លានដុល្លារអាមេរិក កើនឡើង ១៨% ដែលអាចរួមចំណែក ៩,៤% នៃ GDP កម្ពុជា។ ចំនួននេះស្មើនឹង ៧៤% នៃចំណូលទេសចរណ៍ឆ្នាំ២០១៩ ដោយកើនឡើងពី ៦៣% ក្នុងឆ្នាំ២០២៣។ ការងារ ដែលបង្កើតឡើងដោយវិស័យទេសចរណ៍មានចំនួន ០,៥១លាន ក្នុងឆ្នាំ២០២៤ កើនឡើងពី ០,៤៥លាន ក្នុងឆ្នាំ២០២៣។ ទោះជាយ៉ាងណាក៏ដោយ តួលេខនេះនៅតែទាបជាងចំនួនការងារក្នុងឆ្នាំ២០១៩ ដែលមានចំនួនរហូតដល់ ០,៦៣លាន។

12-month arrivals and revenue from Angkor Temple entrance fees (2019 = 100)




ចាប់តាំងពីឆ្នាំ២០២៤ ចំនួនអ្នកធ្វើដំណើរពីបរទេសចូលមកកម្ពុជាបានកើនឡើងខ្ពស់ ដូចមុនមានការរាតត្បាតនៃជំងឺកូវីដ១៩ ប៉ុន្តែវិស័យទេសចរណ៍មិនទាន់បានត្រឡប់ទៅកម្រិតមុនការរាតត្បាតនៅឡើយទេ។ សមាសភាពនៃភ្ញៀវទេសចរក៏មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ផងដែរ។ មុនពេលជំងឺកូវីដ១៩ ការធ្វើដំណើរតាមផ្លូវអាកាសមានចំនួន ២/៣ នៃការធ្វើដំណើរចូលកម្ពុជាសរុប ប៉ុន្តែនិន្នាការនេះបានផ្លាស់ប្តូរក្រោយជំងឺកូវីដ១៩។ ភ្ញៀវទេសចរចិនដែលធ្លាប់មានជិត ៤០% នៃភ្ញៀវទេសចរណ៍សរុប បានថយចុះមកត្រឹម ១៧,៧% នៅក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ ដែលកើនឡើងពី ១២% ក្នុងឆ្នាំ២០២៤។ បច្ចុប្បន្ន ភ្ញៀវចិនឈរនៅលំដាប់ទី៣ បន្ទាប់ពីភ្ញៀវថៃ ២៦,១% និងភ្ញៀវវៀតណាម ១៧,៩%។

នៅក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ ការបង្កើនការនាំចេញ បានជំរុញឱ្យចំនួនរោងចក្រ និងការងារនៅក្នុងវិស័យផលិតកម្មកើនឡើងគួរឱ្យកត់សម្គាល់។ គិតត្រឹមខែមីនា ឆ្នាំ២០២៥ ចំនួនរោងចក្របានកើនឡើងដល់ ២.៥៣៩ ក្នុងនោះ ៥៣,៨% ជារោងចក្រកាត់ដេរ ទំនិញធ្វើដំណើរ និងស្បែកជើង (GTF) កើនឡើង ១៦,៧% បើធៀបនឹងឆ្នាំមុន។ ចំនួនអ្នកមានការងារធ្វើបានកើនឡើងដល់ ១,២លាន ដោយ ៨៣,៧% ជាការងារនៅក្នុងវិស័យផលិតកម្ម GTF កើនឡើង ១៣,៣% បើធៀបនឹងឆ្នាំមុន។ កំណើនការងារភាគច្រើន (៨៩%) គឺបានមកពីវិស័យផលិតកម្ម GTF។ ថ្វីបើចំនួនការងារក្នុងវិស័យផលិតកម្មកើនឡើងក៏ដោយ ក៏ស្ថានភាពទីផ្សារការងារទាំងមូលនៅតែមិនទាន់ល្អប្រសើរ។ ការងារក្នុងវិស័យផលិតកម្មផ្លូវការមានត្រឹមតែ ១៩,៤% នៃការងារមិនមែនកសិកម្ម និង ១២,៥% នៃការងារសរុបប៉ុណ្ណោះ។

តម្រូវការខាងក្រៅខ្ពស់បានទាក់ទាញអ្នកវិនិយោគបរទេសមកកាន់វិស័យនាំចេញ។ ក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ តម្លៃគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយ FDI ក្រោមគម្រោងវិនិយោគមានសិទ្ធិ (QIP) (ក្រៅតំបន់សេដ្ឋកិច្ចពិសេស) បានកើនឡើងដល់ ៦៣០លានដុល្លារអាមេរិក កើនឡើង ១៩%។ ប៉ុន្តែ ចំនួននេះនៅតែទាបជាង មុនពេលមានការរាតត្បាតជំងឺកូវីដ១៩ ដែលស្មើនឹង ៨០១លានដុល្លារអាមេរិក។ ឧស្សាហកម្មកាត់ដេរបានទាក់ទាញបានជិត ២/៣ នៃតម្លៃគម្រោងផ្តល់ហិរញ្ញប្បទានដោយ FDI។ ទោះបីជាមានការកើនឡើងនៃតម្លៃគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយ FDI ក៏ដោយ ក៏តម្លៃវិនិយោគក្នុងស្រុក បានធ្លាក់ចុះ ៩៦,៧% មកត្រឹម ២៣លានដុល្លារអាមេរិកក្នុងត្រីមាសទីមួយ។ ក្រោយការរាតត្បាតនៃជំងឺកូវីដ ១៩ កម្ពុជាមានការផ្លាស់ប្តូរលំហូរ FDI យ៉ាងខ្លាំង ដោយបង្វែរការយកចិត្តទុកដាក់កាន់តែខ្លាំង លើវិស័យសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង។

FDI Inflows by sector (% of share, net excluding financial sector,2024)




ក្នុងចំណោមទំនិញកសិកម្មដែលនាំចេញច្រើនជាងគេទាំងប្រាំរបស់កម្ពុជា ការនាំចេញគ្រាប់ស្វាយចន្ទីបានកើនឡើង ៦,២% ខណៈអង្ករបានកើនឡើង ២០,៨% នៅត្រីមាសទីមួយនៃឆ្នាំ២០២៥។ ការដាំស្រូវប្រាំង និងផលិតអង្ករ បានកើនឡើង ៨% និង៧,៥% រៀងគ្នា។

ការងើបឡើងវិញមួយចំនួននៃការប្រើប្រាស់ឯកជន ដែលបានចាប់ផ្តើមពីឆ្នាំ២០២៤ បានបន្តកើនឡើងដល់ឆ្នាំ២០២៥។ និន្នាការនេះទំនងជាបន្ត ដោយសារការកើនឡើងទំនុកចិត្តរបស់អ្នកប្រើប្រាស់ និងការពង្រីកការនាំចេញផលិតកម្ម ដែលបានរួមចំណែកបង្កើតការងារ និងបង្កើនប្រាក់ចំណូលដល់កម្ពុជា។ ការផ្ញើរប្រាក់ពីបរទេសរបស់កម្មករក៏កើនឡើងផងដែរ។ ការស្ទុះងើបឡើងវិញ នៃការប្រើប្រាស់ឯកជន បានជួយជំរុញសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងបង្កើនតម្រូវការទំនិញប្រើប្រាស់ ដែលស្មើ ៦០% នៃផលិតផលក្នុងស្រុកសរុប។

ការនាំចូលទំនិញបានកើនឡើង ១៨,៥% ក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ ច្រើនជាងការនាំចេញ ដែលកើនឡើងត្រឹមតែ ១១,៦%។ ជាលទ្ធផល ឱនភាពជញ្ជីងពាណិជ្ជកម្មបានកើនឡើង។ នៅឆ្នាំ២០២៥ លំហូរមូលធនដ៏រឹងមាំ ជាពិសេសពី FDI បានជួយបន្ធូរបន្ថយសម្ពាធលើអត្រាប្តូរប្រាក់។ ទុនបម្រុងអន្តរជាតិសរុបរបស់ប្រទេសកម្ពុជាបានកើនឡើងដល់ ២៤,៧ពាន់លានដុល្លារអាមេរិក កើនឡើង ២៦,៤% ក្នុងខែមីនា ឆ្នាំ២០២៥ ដែលស្មើនឹង ៧ខែ នៃការនាំចូលនាពេលអនាគត។

ទោះបីជាកម្ពុជានាំចូលច្រើនជាងការនាំចេញក៏ដោយ ក៏សម្ពាធលើរូបិយបណ្ណ និងអត្រាការប្រាក់មានភាពធូរស្រាល ដោយសារសេដ្ឋកិច្ចកម្ពុជាប្រើប្រាស់ប្រាក់ដុល្លារអាមេរិក និងអនុវត្តតាមគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក។ ទន្ទឹមនឹងនេះ អត្រាប្តូរប្រាក់រៀល និងដុល្លារកើនឡើងតែតិចតួចប៉ុណ្ណោះនៅខែឧសភា ឆ្នាំ២០២៥។ នៅឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជាបានទិញប្រាក់ដុល្លារអាមេរិកច្រើនជាងលក់ចេញ (១១,៩ លានដុល្លារអាមេរិក) ផ្ទុយពីឆ្នាំ២០២៣ ដែលធនាគារលក់បានច្រើនជាងការទិញចូល (១២៣,៩លានដុល្លារអាមេរិក)។ នៅខែមីនា ឆ្នាំ២០២៥ ការផ្គត់ផ្គង់ប្រាក់បានកើនឡើង ១៩% ច្រើនជាងឆ្នាំមុនត្រឹមតែ ១៤% ដោយសារការដាក់ប្រាក់បញ្ញើជាប្រាក់ដុល្លារកើនឡើងច្រើន។

ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០២៣ កំណើនឥណទានក្នុងស្រុកបានធ្លាក់ចុះ បន្ទាប់ពីកើនឡើងបានមួយរយៈ។ នៅខែមីនា ឆ្នាំ២០២៥ កំណើនឥណទាននៅតែមានកម្រិតទាប នៅត្រឹម ៥% ក្នុងមួយឆ្នាំ ខ្ពស់ជាងឆ្នាំមុនបន្តិច (៤%) ដោយសារការធ្លាក់ចុះនៃវិស័យអចលនទ្រព្យ។ គុណភាពទ្រព្យសកម្មក្នុងវិស័យធនាគារក៏ធ្លាក់ចុះផងដែរ។ នៅចុងឆ្នាំ២០២៤ ឥណទានមិនដំណើរការ បានកើនឡើងដល់ ៧,៩% សម្រាប់វិស័យធនាគារ និង ៩% សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ធៀបនឹងឆ្នាំ២០២៣ ត្រឹមតែ ៥,៤% និង ៦,៧% រៀងគ្នាប៉ុណ្ណោះ។

ការថយចុះនៃកំណើនឥណទានបាននាំឱ្យមានការថយចុះ នៃអនុបាតឥណទានធៀបនឹង GDP ដែលបានធ្លាក់ចុះមកត្រឹម ១២០,៤% ក្នុងខែមីនា ឆ្នាំ២០២៥ ធ្លាក់ចុះពី ១២៤,១% ក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៤។ ការកើនឡើងនៃប្រាក់បញ្ញើសន្សំរបស់វិស័យឯកជន បានជំរុញអនុបាតប្រាក់បញ្ញើសន្សំធៀបនឹង GDP កើនឡើងដល់ ១០៨,៦% ក្នុងខែមីនា ឆ្នាំ២០២៥ កើនពី ៩៧,៨%ក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៤។

កំណើនសេដ្ឋកិច្ចនឹងជួយកាត់បន្ថយភាពក្រីក្រ ប៉ុន្តែអត្រាកាត់បន្ថយនៅមានភាពយឺតយ៉ាវ និងខុសគ្នានៅតាមតំបន់ និងវិស័យផ្សេងៗ។ កំណើនសេដ្ឋកិច្ចពិភពលោកយឺតជាងការរំពឹងទុកអាចបណ្តាលឱ្យមានការថយចុះយ៉ាងខ្លាំងនៃការនាំចេញ និងលំហូរវិនិយោគផ្ទាល់ពីបរទេស (FDI) ផងដែរ។



THE WORLD BANK
IBRD • IDA | WORLD BANK GROUP
East Asia & Pacific



# ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានឧបត្ថម្ភនូវបង់អង្គុយ ចំនួន ២០បង់ ដល់ សាកលវិទ្យាល័យបច្ចេកវិទ្យា និង វិទ្យាសាស្ត្រកម្ពុជា



កាលពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៥ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានឧបត្ថម្ភនូវបង់អង្គុយចំនួន ២០បង់ ដល់ សាកលវិទ្យាល័យបច្ចេកវិទ្យា និង វិទ្យាសាស្ត្រកម្ពុជា ដើម្បីប្រើប្រាស់ជាប្រយោជន៍សម្រាប់ និស្សិតប្រើប្រាស់។







# គណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានទទួលស្វាគមន៍ទស្សនកិច្ចសិក្សារបស់មន្ត្រីជំនាញរបស់ធនាគារកណ្ដាលបង់ក្លាដែស

នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥ គណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានទទួលស្វាគមន៍ទស្សនកិច្ចសិក្សារបស់មន្ត្រីជំនាញរបស់ធនាគារកណ្ដាលបង់ក្លាដែស ក្នុងគម្រោង «ការបង្កើតការងារក្រោយជំងឺកូវីដ១៩»។

ក្នុងទស្សនកិច្ចសិក្សានេះ គណៈគ្រប់គ្រងធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានចែករំលែកបទពិសោធន៍ របស់កម្ពុជា ក្នុងការស្តារសេដ្ឋកិច្ចឡើងវិញក្រោយជំងឺកូវីដ១៩ សម្រាប់សហគ្រាសធុនតូច និងមធ្យម។






មណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ
钻石岛会展中心
Diamond Island Convention and Exhibition Center

# ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានឧបត្ថម្ភ បង់បង្អួយចំនួន ២៧ ដល់សហគមន៍កោះពេជ្រ

នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៥ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានឧបត្ថម្ភ បង់បង្អួយចំនួន ២៧ ដល់សហគមន៍កោះពេជ្រ ដើម្បីដាក់ពង្រាយតាមផ្លូវដើរមាត់ទន្លេ សម្រាប់សាធារណជន។





# ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ និង ក្រុមហ៊ុនអាយជី អាណាចក្រចិក បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូយុទ្ធសាស្ត្រផ្នែកបច្ចេកវិទ្យា




ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ និង ក្រុមហ៊ុនអាយជី អាណាចក្រចិក បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូយុទ្ធសាស្ត្រផ្នែកបច្ចេកវិទ្យា នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ នៅស្នាក់ការកណ្តាលរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ។

កិច្ចសហការនេះធ្វើឡើងក្នុងគោលបំណងពង្រឹងភាពជាដៃគូក្នុងការផ្គត់ផ្គង់ដំណោះស្រាយបច្ចេកវិទ្យារបស់អាយជី អាណាចក្រចិក សម្រាប់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ឱ្យកាន់តែរឹងមាំ និងទូលំទូលាយ ព្រមទាំងពង្រីកកិច្ចសហការអភិវឌ្ឍន៍ និងអនុវត្តបច្ចេកវិទ្យាទំនើបៗស្របតាមទិសដៅយុទ្ធសាស្ត្រឌីជីថលរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ក៏ដូចជារួមចំណែកអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា។

លោក តូច ចៅចេក ប្រធាននាយកប្រតិបត្តិ នៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានមានប្រសាសន៍ថា «ធនាគារ ប្រៃសណីយ៍កម្ពុជា ពិតជាមានសេចក្តីសោមនស្សរីករាយ ដែលបានសហការជាមួយក្រុមហ៊ុនអាយជី អាណាចក្រចិក។ យើងជឿជាក់ថាភាពជាដៃគូនេះនឹងនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន សម្រាប់បច្ចេកវិទ្យាឌីជីថលរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ដែលនេះនឹងកាន់តែផ្តល់ភាពងាយស្រួល និងសុវត្ថិភាពជូនអតិថិជនរបស់ធនាគារ។»








ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
東埔寨郵政銀行 CAMBODIA POST BANK PLC.

# ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ទទួលបាន ពានរង្វាន់អន្តរជាតិដែលជា ធនាគារលក់រាយល្អបំផុតប្រចាំឆ្នាំ២០២៥ (Best Retail Bank 2025)






អបអរសាទរ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ទទួលបានពានរង្វាន់អន្តរជាតិដែលជា «ធនាគារលក់រាយល្អបំផុតប្រចាំឆ្នាំ២០២៥ (Best Retail Bank 2025) » ក្នុងទីក្រុងអាតាឡង់តា រដ្ឋចចា សហរដ្ឋអាមេរិក ពីស្ថាប័ន World Confederation of Business នាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៥។





ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
東埔寨郵政銀行 CAMBODIA POST BANK PLC.

# សូមអបអរសាទរចំពោះ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានឈ្នះពានរង្វាន់

## “Best Quality Leadership Award 2025”








អបអរសាទរ! ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ (CPBank) បានឈ្នះពានរង្វាន់ “Best Quality Leadership Award 2025” កម្រិតមាស ពីស្ថាប័ន European Society for Quality Research (ESQR) ប្រទេសស៊ុយអែត នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥។

ពានរង្វាន់នេះ ជាការទទួលស្គាល់ចំពោះការខិតខំប្រឹងប្រែង និងប្តេជ្ញាចិត្តរបស់ធនាគារ ក្នុងការពង្រឹងគុណភាពសេវាកម្ម និងការអភិវឌ្ឍន៍ផលិតផលយ៉ាងច្រើនសម្បូរបែបស្របតាមតម្រូវការអតិថិជន។



# ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានចូលរួមឧបត្ថម្ភ ដល់គម្រោងកិច្ចការសង្គម របស់សមាគមធនាគារនៅកម្ពុជា

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានចូលរួមឧបត្ថម្ភ ដល់គម្រោងកិច្ចការសង្គមរបស់សមាគមធនាគារនៅកម្ពុជា ដោយឧបត្ថម្ភសម្ភារៈសិក្សាដល់សាលាចំនួនប្រាំពីរ ស្ថិតនៅស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។



សាលាទាំងប្រាំពីររួមមាន សាលាបឋមសិក្សាចារជ្រុំ សាលាបឋមសិក្សាអូរគ្រូកៃ សាលាបឋមសិក្សាច្រនាង សាលាបឋមសិក្សាសំបូរ សាលាបឋមសិក្សាត្រពាំងជ្រូក សាលាបឋមសិក្សាព្រៃក និង អនុវិទ្យាល័យប្រាសាទសំបូរ។ សាលានីមួយៗទទួលបានទូរទស្សន៍មួយគ្រឿងដាក់ក្នុងបណ្ណាល័យសម្រាប់សិស្សានុសិស្សរៀនភាសាអង់គ្លេសតាមប្រព័ន្ធអ៊ីនធឺណិត តុសិស្ស និងតុគ្រូ ខណៈសិស្សានុសិស្សម្នាក់ៗទទួលបានសម្ភារៈសិក្សា ដូចជា កាតាប សៀវភៅ កាបូបប៊ិច ប៊ិច និង ដបទឹក។





ពិធីប្រគល់អំណោយបានប្រព្រឹត្តឡើង នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥ នៅសាលាបឋមសិក្សាចារជ្រុំ ខេត្តកំពង់ធំ ក្រោមអធិបតីយភាពរបស់លោកជំទាវ សាយ សំអាត ទេសាភិបាលរង ធនាគារជាតិ នៃកម្ពុជា និងមានការចូលរួមដោយតំណាងសមាគមធនាគារនៅកម្ពុជា និងធនាគារនានាផងដែរ។





# វគ្គបណ្តុះបណ្តាលប្រចាំឆ្នាំដល់មន្ត្រីឥណទាន របស់ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានរៀបចំនូវវគ្គបណ្តុះបណ្តាលប្រចាំឆ្នាំដល់មន្ត្រីឥណទានលើតួនាទី និងភារៈកិច្ច និងការជំរុញផលិតភាពមន្ត្រីឥណទាន ដែលប្រព្រឹត្តទៅតាមភូមិភាគនីមួយៗនៃតំបន់ប្រតិបត្តិការរបស់គ្រឹះស្ថាន។ វគ្គបណ្តុះបណ្តាលនេះបានចាប់ផ្តើមពីភូមិភាគភ្នំពេញ នៅថ្ងៃសៅរ៍ ៦រោច ខែពិសាខ ឆ្នាំម្សាញ់ ត្រូវនឹងថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៥។ ក្នុងកិច្ចនៃការបើកវគ្គបណ្តុះបណ្តាលនេះ លោក ឃូ ប៊ុនទ្រី ប្រធាននាយកប្រតិបត្តិ នៃគ្រឹះស្ថាន បានលើកឡើងពីភាពសំខាន់នៃតួនាទីជាមន្ត្រីឥណទានប្រកបដោយការទទួលខុសត្រូវ និងការជំរុញកំណើននៃផលិតភាពជាមធ្យមក្នុងមន្ត្រីឥណទានម្នាក់ៗ ស្របទៅនឹងផែនការជារួមរបស់គ្រឹះស្ថានទាំងមូល។









# គណនីសកម្ម

អតិថិជនអាចប្រើប្រាស់ប្រាក់ក្នុងគណនីជារៀងរាល់ថ្ងៃ
និងទទួលបានអត្រាការប្រាក់ខ្ពស់ជាងគេ

**ការប្រាក់**
**ប្រចាំឆ្នាំខ្ពស់រហូតដល់**

**4.75%** ប្រាក់រៀល

**3.75%** ប្រាក់ដុល្លារ




**ផ្តល់ជូនពិសេសសម្រាប់**
**ដៃគូអាជីវកម្ម CPBank**